ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ

---

រឿងព្រហ្មទណ្ឌ
លេខ៨១/២០-០១-២០១១
សាលដីកាលេខ១០៨ក្រ.III.យ
ចុះថ្ងៃទី២៦-១២-២០១១

តាងនាមប្រជារាស្ត្រខ្មែរ
សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ០៦ក្រចុះថ្ងៃទី០៩-០២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍កាលពីថ្ងៃទី២៦-១២-២០១១ដែលមានសមាសភាពដូចតទៅ៖

**<u>សមាសភាពក្រុមប្រឹក្សាជំនុំជំរះ</u>**

**លោក [redacted] ប្រធាន**

**លោក [redacted] ចៅក្រមប្រឹក្សា**

**លោកស្រី [redacted] ចៅក្រមប្រឹក្សា**

**តំណាងមហាអយ្យការ**

**លោក [redacted]**

**ក្រឡាបញ្ជី**

**លោកស្រី [redacted]**

**១-ជនជាប់ចោទឈ្មោះ [redacted] ផាង (ដើមបណ្តឹងឧទ្ធរណ៍)**ភេទស្រី អាយុ៥០ឆ្នាំ ជាតិខ្មែរ កើតនៅភូមិរាំងខាងត្បូង ឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ ទីលំនៅសព្វថ្ងៃ [redacted] ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះសៅ [redacted](ស)ម្តាយឈ្មោ[redacted]) ប្តីឈ្មោ[redacted] មានកូន៨នាក់។ទោសពីមុនគ្មាន។ ឃុំខ្លួនថ្ងៃទី០២-៣-២០១០ ។

**២-ជនជាប់ចោទឈ្មោះ [redacted] ធីហឿង (ចុងបណ្តឹងឧទ្ធរណ៍)**ភេទស្រី អាយុ៤៨ឆ្នាំ ជាតិវៀតណាម កើតនៅប្រទេសវៀតណាម ទីលំនៅសព្វ [redacted] ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (ស)ម្តាយឈ្មោះ [redacted](រ)។ទោសពីមុនគ្មាន។ឃុំខ្លួនថ្ងៃទី០២-៣-២០១០ ។

**៣-ជនជាប់ចោទឈ្មោះ [redacted] ធី (ដើមបណ្តឹងឧទ្ធរណ៍)**ភេទស្រី អាយុ៤៣ឆ្នាំ ជាតិ



Scanned by CamScanner

ខ្មែរ កើតនៅភូមិពាលញែក ឃុំពាលញែក ស្រុកបាកាន ខេត្តពោធិសាត់ ទីលំនៅសព្វថ្ងៃ ផ្ទះ [redacted] ខណ្ឌ៧មករា រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ហុន(រ)ម្ដាយឈ្មោះ [redacted](ស) ប្ដីឈ្មោះ [redacted] មានកូន៣នាក់។ទោសពីមុនគ្មាន។ ឃុំខ្លួនថ្ងៃទី០២-៣-២០១០ ។

**៤-ជនជាប់ចោទឈ្មោះ** [redacted] **អេះ(ចុងបណ្ដឹងឧទ្ធរណ៍)**ភេទស្រី អាយុ៥៩ឆ្នាំ ជាតិខ្មែរ កើតនៅស្រុកព្រែកជ្រូក ប្រទេសវៀតណាម ទីលំនៅសព្វថ្ងៃ [redacted] អញ្ញាញ សង្កាត់ត្រពាំងក្រសាំង ខណ្ឌដង្កោ រាជធានីភ្នំពេញ ប្ដីឈ្មោះ [redacted] មានកូន៥នាក់ ឪពុកឈ្មោះ [redacted] (ស)ម្ដាយឈ្មោះ [redacted] ស)។ទោសពីមុនគ្មាន។ឃុំខ្លួនថ្ងៃទី០២-៣-២០១០ ។

**៥-ជនជាប់ចោទឈ្មោះ** [redacted] **ពៅ (ដើមបណ្ដឹងឧទ្ធរណ៍)**ភេទស្រី អាយុ៥១ឆ្នាំ ជាតិខ្មែរ កើតនៅភូមិជីឃ្មល់ ឃុំគោកព្រិច ស្រុកគីរីវង្ស ខេត្តតាកែវ ទីលំនៅសព្វ ថ្ងៃផ្ទះលេខ [redacted] ង ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] កែវ(រ)ម្ដាយឈ្មោះ [redacted] ប្ដីឈ្មោះ [redacted] មានកូន ១ នាក់ ។ ទោសពីមុនគ្មាន។ឃុំខ្លួនថ្ងៃទី០២-៣-២០១០ ។

ត្រូវចោទពីបទ អូសទាញពេស្យាចារកុមារ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៥-០២-២០១០ បទល្មើសដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា៣៥ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរ និង អំពើធ្វើអាជីវកម្មផ្លូវភេទ។

បានឃើញពាក្យបណ្ដឹងឧទ្ធរណ៍លេខ៨៥៥ចុះថ្ងៃទី២៥-១១-២០១០របស់ជនជាប់ចោទឈ្មោះ [redacted] ពៅ បណ្ដឹងឧទ្ធរណ៍លេខ៨៥៩ចុះថ្ងៃទី២៦-១១-២០១០របស់ជនជាប់ចោទឈ្មោះ [redacted] ធី បណ្ដឹងឧទ្ធរណ៍លេខ៨៦១ចុះថ្ងៃទី២៩-១១-២០១០របស់ជនជាប់ចោទឈ្មោះ [redacted] ផាង គ្រប់ចំណុចសេចក្ដីសំរេចទាំងមូល បណ្ដឹងឧទ្ធរណ៍លេខ៩០០ចុះថ្ងៃទី១៣-១២-២០១០របស់លោក [redacted] សារឿន ជាមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឌីក ប្ដឹងឧទ្ធរណ៍គ្រប់ចំណុចសំណងជំងឺចិត្ត នឹងសាលក្រមព្រហ្មទណ្ឌលេខ១២៨ក្រ១/១៥.១១.២០១០របស់សាលាដំបូងរាជធានីភ្នំពេញ។

**<u>៦ដំណើររឿងមានដូចតទៅៈ</u>**

កាលពីថ្ងៃទី២៥-០២-២០១០ការិយាល័យប្រឆាំងការជួញដូរមនុស្ស និង ការពារអនីតិជនបានចុះអនុវត្តតាមចំណារលេខ៦៨អយយ/២៤-០២-២០១០របស់ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញបានចុះបង្ក្រាបករណីជួញដូរមួយនៅរាជធានីភ្នំពេញ ដែលកំពុងអូសទាញជនរងគ្រោះដែលមានឈ្មោះ [redacted] ធីទៀកម៉ាយ និង ឈ្មោះ [redacted] ពៅ ដែលជាអនីតិជនអាយុក្រោម១៨ឆ្នាំ ទៅធ្វើពេស្យាចារ ហើយកំលាំងសមត្ថកិច្ចបានបង្ក្រាបជាក់ស្ដែង និងឃាត់ខ្លួនជនល្មើសចំនួន៥នាក់ មានឈ្មោះ [redacted] ពៅ ,ឈ្មោះ [redacted] ធី,ឈ្មោះ [redacted] អេះ,ឈ្មោះ [redacted] ផាង និង ឈ្មោះ [redacted] ធីហៀង មកកាន់ការិយាល័យតែម្ដង។





Scanned by CamScanner

G8/8

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ១២៨ក្រ១/១៥-១១-២០១០របស់សាលាដំបូងរាជធានីភ្នំពេញ បានសំរេចសេចក្តីដូចតទៅៈ

១-ផ្តន្ទាទោសៈ

ក/ឈ្មោះ[redacted]ផាង ភេទស្រី អាយុ៤០ឆ្នាំ ជាតិខ្មែរ.

ខ/ឈ្មោះ [redacted]ធី ភេទស្រី អាយុ៤៣ឆ្នាំ ជាតិខ្មែរ.

គ/ឈ្មោះ[redacted] ពៅ ភេទស្រី អាយុ៥១ឆ្នាំ ជាតិខ្មែរ.

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល៧ឆ្នាំ(ប្រាំពីរឆ្នាំ).

ឃ/ឈ្មោះ [redacted] ធីហៀង ភេទស្រី អាយុ៤៨ឆ្នាំ.

ង/ឈ្មោះ [redacted]អេះ ភេទស្រី អាយុ៥៩ឆ្នាំ.

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល៣ឆ្នាំ(បីឆ្នាំ) និង ពិន័យជាប្រាក់ក្នុងម្នាក់ៗចំនួន៤.០០០.០០០៛(បួនលានរៀល) ពីបទអូសទាញពេស្យាចារកុមារ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៥-០២-២០១០ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរ និង អំពើធ្វើអាជីវកម្មផ្លូវភេទ។

២-លើកចោលការទាមទាររបស់មេធាវី[redacted] សារៀន របស់ជនរងគ្រោះឈ្មោះ[redacted] ពៅ។

៣-វត្ថុតាងៈ

ក/ទូរសព្ទដៃម៉ាកណូគាចំនួន៣គ្រឿង ដូចក្នុងកំណត់ហេតុទទួលវត្ថុតាងលេខ០៩៩អយញចុះថ្ងៃទី២៧-០២-២០១០របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ត្រូវរឹបអូសជាសម្បត្តិរដ្ឋ។

ខ/សៀវភៅកាត់លេខទូរសព្ទចំនួនចំនួន៣ក្បាល ត្រូវរឹបអូស និង បំផ្លាញចោល។

៤-សាលក្រមនេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៥-១០-២០១០ចំពោះមុខជនជាប់ចោទ មេធាវីការពារសិទ្ធិជនជាប់ចោទ ជនរងគ្រោះ មេធាវីការពារជនរងគ្រោះ និង ប្រកាសជាសាធារណៈនៅថ្ងៃទី១៥-១១-២០១០ ចំពោះមុខជនជាប់ចោទ មេធាវីការពារសិទ្ធិជនជាប់ចោទ ជនរងគ្រោះ មេធាវីការពារជនរងគ្រោះ បើកប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

បើកសិទ្ធិប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

បានឃើញពាក្យបណ្តឹងឧទ្ធរណ៍លេខ៨៤៥ចុះថ្ងៃទី២៥-១១-២០១០របស់ជនជាប់ចោទឈ្មោះ[redacted] ពៅ បណ្តឹងឧទ្ធរណ៍លេខ៨៥៩ចុះថ្ងៃទី២៦-១១-២០១០របស់ជនជាប់ចោទឈ្មោះ [redacted] ធី បណ្តឹងឧទ្ធរណ៍លេខ៨៦១ចុះថ្ងៃទី២៩-១១-២០១០របស់ជនជាប់ចោទឈ្មោះ[redacted]ផាង គ្រប់ចំណុចសេចក្តីសំរេចទាំងមូល បណ្តឹងឧទ្ធរណ៍លេខ៩០០ចុះថ្ងៃទី១៣-១២-២០១០របស់លោក [redacted] សារៀន ជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ឌឹក ប្តឹងឧទ្ធរណ៍គ្រប់ចំណុចសំណងជំងឺចិត្ត នឹងសាលក្រមព្រហ្មទណ្ឌលេខ១២៨ក្រ១/១៥.១១.២០១០របស់សាលាដំបូងរាជធានីភ្នំពេញ។

បានឃើញរបាយការណ៍របស់សាលាឧទ្ធរណ៍។

បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។





Scanned by CamScanner

68/7

នាពេលសវនាការ

ចៅក្រមអានរបាយការណ៍របស់សាលាឧទ្ធរណ៍.

ជនជាប់ចោទឈ្មោះ[redacted]ញាង ឆ្លើយថា៖ខ្លួនមានមេធាវីឃុត កែវសុត្ថាការពារ។ខ្លួនមានអាយុ៤៣ឆ្នាំ ជាតិខ្មែរ កើតនៅភូមិ[redacted]ស្រុកសន្ទុក ខេត្តកំពង់ធំ ទីលំនៅសព្វថ្ងៃ [redacted] ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] (ស)ម្តាយឈ្មោះ[redacted](រ) ប្តីឈ្មោះ[redacted] មានកូន៤នាក់។ទោសពីមុនគ្មាន។ ឃុំខ្លួនថ្ងៃទី០២-៣-២០១០ ។ខ្លួនប្តឹងឧទ្ធរណ៍ដើម្បីសុំតុលាការមេត្តាសំរាលទោសដល់ខ្លួនឲ្យបានទាប។ខ្លួនមានមុខរបរជាអ្នកលក់ប្រហិតនៅផ្សារដេប៉ូ។យាយហាយបានឲ្យកូនឈ្មោះម៉ាយមកស៊ីឈ្នួល គោសប្រហិតសាច់ត្រីឲ្យខ្លួន១មានកម្មករតែម្នាក់គត់ គឺឈ្មោះម៉ាយនេះឯង ខ្លួនឲ្យប្រាក់ខែ១ខែជាងដប់ម៉ឺនរៀល។ឈ្មោះម៉ាយជួនកាលរាដេកនៅផ្ទះខ្លួន ជួនកាលរាដេកនៅផ្ទះម្តាយរាាឯឈ្មោះ[redacted]ពៅខ្លួនមិនស្គាល់ទេ។ខ្លួនមិនដែលស្គាល់ឈ្មោះ[redacted] ពៅ និង [redacted] ធីទេ។ឈ្មោះម៉ាយមិនដែលទៅផ្សារជាមួយខ្លួនទេ។ខ្លួនមិនបាននាំឈ្មោះម៉ាយ និង សីងពៅទៅឃុំឃាំងទេ។ជនរងគ្រោះទាំង២នាក់នេះឆ្លើយមិនត្រឹមត្រូវទេ។ប៉ូលីសចាប់ខ្លួនពេលខ្លួនកំពុងឈរនៅមុខសណ្ឋាគារឡាក់គីស្តារ គឺខ្លួនឈរចាំជូនគេរកទិញផ្ទះ ខ្លួនជាតួកជេរនាំគេទិញផ្ទះ។សំណូមពរសុំបានរួចផុតពីបទចោទប្រកាន់ និង សុំឲ្យដោះលែងខ្លួនឲ្យមានសេរីភាពវិញផង។

ជនជាប់ចោទឈ្មោះ[redacted] ពៅ ឆ្លើយថា៖ខ្លួនមានមេធាវីអ៊ុំ ប៊ុនធឿនការពារ។ខ្លួនមានអាយុ៥១ឆ្នាំ ជាតិខ្មែរ កើតនៅភូមិជីឃ្មល់ ឃុំគោកព្រិច ស្រុកគីរីវង្ស ខេត្តតាកែវ ទីលំនៅសព្វថ្ងៃផ្ទះលេ[redacted]សង្កាត់បឹងកេងកង ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted](រ)ម្តាយឈ្មោះ[redacted](រ)ប្តីឈ្មោះ[redacted] មានកូន១នាក់។ ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី០២-៣-២០១០។ខ្លួនប្តឹងឧទ្ធរណ៍ ព្រោះខ្លួនពុំបានប្រព្រឹត្តអ្វីមិនល្អទេ។ខ្លួនសុំបដិសេធចំលើយរបស់ខ្លួនដែលឆ្លើយនៅមុខប៉ូលីស ព្រោះជាចំលើយដែលមានការបង្ខិតបង្ខំពីប៉ូលីស។ប៉ូលីសចាប់ខ្លួនពេលខ្លួនកំពុងឈរនៅមុខសណ្ឋាគារឡាក់គីស្តារ គឺខ្លួនឈរចាំជូនគេរកទិញផ្ទះ ខ្លួនជាតួកជេរនាំគេទិញផ្ទះ។ខ្លួនណាត់ឈ្មោះ[redacted] ធីម៉ោង២រសៀល ដើម្បីជូនគេទៅមើលរកទិញផ្ទះ។ខ្លួនមិនដែលស្គាល់ឈ្មោះ[redacted] ពៅទេ។ខ្លួនមិនបាននាំឈ្មោះម៉ាយ និង សីង ពៅទៅឃុំឃាំងទេ។ខ្លួនមិនស្គាល់លេខទូរស័ព្ទរបស់ឈ្មោះ[redacted] ពៅទេ។ជនរងគ្រោះទាំង២នាក់នេះឆ្លើយមិនត្រឹមត្រូវទេ។សំណូមពរសុំបានរួចផុតពីបទចោទប្រកាន់ និង សុំឲ្យដោះលែងខ្លួនឲ្យមានសេរីភាពវិញផង។

ជនជាប់ចោទឈ្មោះ[redacted] ធី ឆ្លើយថា៖ខ្លួនមានមេធាវីឃ្លូ[redacted] ការពារ។ខ្លួនមានអាយុ៤៣ឆ្នាំ ជាតិខ្មែរ កើតនៅភូមិពាលញែក ឃុំពាលញែក ស្រុកបាកាន ខេត្តពោធិ៍សាត់ ទីលំនៅសព្វថ្ងៃ[redacted]សង្កាត់អូរឫស្សី ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted](រ)ម្តាយឈ្មោះ [redacted](ស) ប្តីឈ្មោះ[redacted] មានកូន៣នាក់។ទោសពីមុនគ្មាន។ ឃុំខ្លួនថ្ងៃទី០២-៣-២០១០។ខ្លួនប្តឹងឧទ្ធរណ៍ ព្រោះខ្លួនពុំបានប្រព្រឹត្តអ្វីមិនល្អទេ។ប៉ូលីសចាប់ខ្លួនពេលខ្លួនកំពុងឈរនៅមុខសណ្ឋាគារឡាក់គីស្តារ គឺខ្លួនឈរចាំជូនគេរកទិញផ្ទះ ខ្លួនជាតួក



148

Scanned by CamScanner

ជេរនាំគេទិញផ្ទះ។ខ្លួនណាត់ឈ្មោះ [redacted] ពៅ ម៉ោង២រសៀល ដើម្បីជូនគេទៅមើលកេទិញផ្ទះ។ខ្លួនមិនបាននាំឈ្មោះម៉ាយ និង ស៊ីងពៅទៅយុយក្រមុំទេ។ខ្លួនចេញពីផ្ទះម៉ោងប្រហែល២ជាង ជនរងគ្រោះទាំង២នាក់មិនបានមកជាមួយខ្លួនទេ។ខ្លួនសុំបដិសេធចំលើយរបស់ខ្លួនដែលឆ្លើយនៅមុខប៉ូលីស ព្រោះជាចំលើយដែលមានការបង្ខិតបង្ខំពីប៉ូលីស ខ្លួនមិនបាននាំជនរងគ្រោះទៅពេទ្យទេ។ខ្លួនមិនទទួលស្គាល់ចំលើយរបស់ខ្លួនដែលឆ្លើយនៅមុខប៉ូលីសទេព្រោះប៉ូលីសបង្ខំឲ្យខ្លួនឆ្លើយ។សំណូមពរសុំបានរួចផុតពីបទចោទប្រកាន់ និង សុំឲ្យដោះលែងខ្លួនឲ្យមានសេរីភាពវិញផង។

ជនរងគ្រោះឈ្មោះ[redacted] ទៀកធីម៉ាយឆ្លើយថា៖ពេលកើតហេតុខ្លួនមានអាយុ១៥ឆ្នាំ ខ្លួនកើតសង្កាត់ច្បារអំពៅ ភ្នំពេញ ម្ដាយខ្លួនជនជាតិវៀតណាម ឈ្មោះ[redacted] (ז) ឪពុកខ្លួនឈ្មោះ[redacted] ខ្លួនស្នាក់នៅ[redacted] ភ្នំពេញ មុខរបរនៅផ្ទះ នៅលីវ។ខ្លួនមានមេធាវី[redacted]សារឿន ការពារ។ដំបូងម្ដាយខ្លួនឈឺ គ្មានលុយទិញថ្នាំ និង ថ្លៃឈ្នួលផ្ទះ ខ្លួនក៏ទៅស៊ីឈ្នួលកោសប្រហិតឲ្យយាយផានបានប្រហែល១ខែដែរ។ខ្លួនយល់ព្រមឲ្យគេយុយក្រមុំដើម្បីយកលុយជួយម្ដាយខ្លួនកំពុងឈឺ។បដិសេធចំលើយរបស់ខ្លួនដែលឆ្លើយនៅមុខប៉ូលីសរួចហើយ ព្រោះជាចំលើយដែលមានការបង្ខិតបង្ខំពីប៉ូលីស។ពេលប៉ូលីសសួរយកចំលើយ មិនមានម្ដាយនៅជិតទេ។ខ្លួនមានតែ២នាក់ម្ដាយកូនប៉ុណ្ណោះ។យាយចូវជាអ្នកនាំខ្លួនទៅជួបយាយផាន។យាយចូវជាអ្នកជិតខាងផ្ទះម្ដាយខ្លួន។ម្ដាយខ្លួនមិនបានលក់កូនស្រីទេឲ្យទៅយុយក្រមុំទេ។យាយផាន យាយធី និង យាយពៅពិតជាទាក់ទងរកម៉ូយយុយក្រមុំខ្លួនមែន។ ហើយនាំខ្លួន និង[redacted] ពៅ ទៅឲ្យភ្ញៀវមើលនៅហាងកាហ្វេ ហើយភ្ញៀវក៏ត្រូវចិត្តពួកខ្លួន ភ្ញៀវក៏ឲ្យលុយយាយទាំង៣នាក់នេះ តែខ្លួនមិនដឹងចំនួនលុយទេ ព្រោះពួកខ្លួនអង្គុយនៅឆ្ងាយពីភ្ញៀវ៣នាក់ និង ពួកគាត់។ យាយផាន យាយធី និង យាយពៅ គាត់បាននាំពួកខ្លួនទៅឲ្យពេទ្យពិនិត្យប្រដាប់ភេទពួកខ្លួនទៀត តែខ្លួនមិនស្គាល់ពេទ្យឈ្មោះអ្វីទេ ហើយយាយពៅ និង យាយធីគាត់ឲ្យពួកខ្លួនទៅបន្ទប់ទឹកលាបក្រែមម្សៅ រួចជិះតុកៗទៅជួបភ្ញៀវនៅសណ្ឋាគារឡាក់គីស្ដារ ម៉ោងប្រហែល១ថ្ងៃ ឯយាយផាងគាត់ទៅផ្ទះមុនបាត់ហើយ។ខ្លួនសុំឲ្យម្ដាយខ្លួនរួចពីបទចោទ និង សុំឲ្យលែងគាត់ព្រោះគាត់មិនបានលក់កូនទេ។សំណូមពរទារជំងឺចិត្តពីយាយផាន យាយធី និង យាយពៅ ចំនួន៥០០០ដុល្លារអាមេរិក ខ្លួនមិនទារពីម្ដាយខ្លួនទេ។

ជនរងគ្រោះឈ្មោះ[redacted] ពៅ ឆ្លើយថា៖ពេលកើតហេតុខ្លួនមានអាយុ១៨ឆ្នាំ ខ្លួនកើតសង្កាត់ទន្លេបាសាក់ ភ្នំពេញ ម្ដាយខ្លួនជនជាតិវៀតណាម ឈ្មោះ[redacted] (ז) ឪពុកខ្លួនឈ្មោះ [redacted] (ז) ខ្លួនស្នាក់នៅ[redacted]ណ្ឌចំការមន ភ្នំពេញ មុខរបរនៅផ្ទះ នៅលីវ។ខ្លួនមានមេធាវី[redacted]ហារឿន ការពារ។ខ្លួនស្គាល់យាយចែត ពៅ និង យាយធីតាំងពីខ្លួនកំពុងយួរផ្លែដូងខ្ចីលក់នៅផ្សារថ្មី។ម្ដាយខ្លួនមិនស្គាល់យាយ ចែត ពៅទេ។ដំបូងយាយធី និង យាយពៅបានទិញដូងខ្លួន ហើយពួកគាត់សួរខ្លួនថាម៉ែមានខ្ចីលុយគេទេ? ខ្លួនក៏ឆ្លើយថា ម៉ែខ្លួនខ្ចីលុយគេច្រើនណាស់ គាត់ប្រាប់ខ្លួនថាបើចង់រកលុយជួយម៉ែគាត់ឲ្យខ្លួនទៅយុយក្រមុំបានលុយច្រើន ។ម្ដាយខ្លួនក៏លក់ដូងដែរ ម្ដាយខ្លួនមិនដឹងថាខ្លួនទៅណាទេ។ដោយ





Scanned by CamScanner

68/5

សារខ្លួនចង់បានលុយច្រើនផង ខ្លួនក៏ទាក់ទងយាយធី និង យាយពៅតាមទូរស័ព្ទ។ខ្លួនយល់ព្រមឲ្យគេយុយក្រមុំដើម្បីយកលុយជួយម្តាយ យាយផាន យាយធី និង យាយពៅពិតជាទាក់ទងរកម៉ូយយុយក្រមុំខ្លួនមែន។ម្តាយខ្លួនមិនបានលក់កូនស្រីឲ្យទៅយុយក្រមុំទេ។ខ្លួនមិនទទួលស្គាល់ចំលើយដែលខ្លួនឆ្លើយនៅប៉ូលីសទេ។ប៉ូលីសបង្ខំឲ្យខ្លួនឆ្លើយ ហើយប្រាប់ខ្លួនថាឆ្លើយទៅនឹងឆាប់បានត្រឡប់ទៅផ្ទះវិញ ។ពេលប៉ូលីសសួរយកចំលើយ មិនមានម្តាយ នៅជិតទេ។ខ្លួនចង់ទៅយុយក្រមុំមែន ដើម្បីបានលុយច្រើន។យាយផាន យាយធី និង យាយពៅពិតជាបាននាំខ្លួន និងម៉ាយ ទៅឲ្យភ្ញៀវមើលនៅហាងកាហ្វេ ហើយភ្ញៀវក៏ត្រូវចិត្តពួកខ្លួន ភ្ញៀវក៏ឲ្យលុយយាយទាំង៣នាក់នេះ តែខ្លួនមិនដឹងចំនួនលុយទេ ព្រោះពួកខ្លួនអង្គុយនៅឆ្ងាយពីភ្ញៀវ៣នាក់ និង ពួកគាត់។ យាយផាន យាយធី និង យាយពៅ គាត់បាននាំពួកខ្លួនទៅឲ្យពេទ្យពិនិត្យប្រដាប់ភេទពួកខ្លួនទៀត តែខ្លួនមិនស្គាល់ពេទ្យឈ្មោះអ្វីទេ ហើយយាយពៅ និង យាយធីគាត់ឲ្យពួកខ្លួនទៅបន្ទប់ទឹកលាបក្រែមម្សៅ រួចជិះតុកៗទៅជួបភ្ញៀវនៅសណ្ឋាគារឡាក់គីស្ការ ម៉ោងប្រហែល១ថ្ងៃ ឯយាយផាងគាត់ទៅផ្ទះមុនបាត់ហើយ។ខ្លួនសំណូមពរទាររំងឺចិត្តពីយាយផានយាយធី និង យាយពៅ ចំនួន៥០០០ដុល្លាអាមេរិក ខ្លួនមិនទារពីម្តាយខ្លួនទេ ខ្លួនសុំឲ្យម្តាយខ្លួនរួចពីបទចោទ និង សុំឲ្យលែងគាត់ព្រោះគាត់មិនបានលក់កូនទេ។

ជនជាប់ចោទឈ្មោះ[redacted] ធីហ្មៀង ឆ្លើយថាៈខ្លួនជាម្តាយរបស់ឈ្មោះ[redacted] ម៉ាយ។ខ្លួនមិនបានប្តឹងឧទ្ធរណ៍ទេ។ដំបូងខ្លួនដេកឈឺនៅផ្ទះ ខ្លួនមិនបានជូនកូនទៅជួយកោសប្រហិតត្រីគេទេ។ខ្លួនដេកឈឺនៅផ្ទះជួលគេនៅទួលគោក ។ម៉ាយជាកូនរបស់ខ្លួនវាប្រាប់ខ្លួនថាវាទៅជួយកោសប្រហិតត្រីឲ្យយាយផាង។ខ្លួនមិនស្គាល់យាយចូវទេ។ពេលឮថាប៉ូលីសចាប់កូនខ្លួនក៏ដកសេរ៉ូមទៅមើលកូននៅកន្លែងប៉ូលីស ។ខ្លួនមិនបានលក់កូនស្រី ឲ្យទៅយុយក្រមុំទេ។យាយផាងធ្លាប់មកមើលខ្លួនឈឺនៅផ្ទះដែរ យាយផាងឲ្យលុយកូនខ្លួន១ខែ៥០ដុល្លាសំរាប់ថ្លៃជួយកោសប្រហិតត្រីឲ្យ។

ជនជាប់ចោទឈ្មោះ[redacted] អេៈ ឆ្លើយថាៈខ្លួនជាម្តាយរបស់ឈ្មោះ[redacted] ពៅ។ ។ខ្លួនមានអាយុ៥៩ឆ្នាំ ជាតិខ្មែរ កើតនៅស្រុកព្រៃកជ្រូក ប្រទេសវៀតណាម ទីលំនៅសព្វថ្ងៃផ្ទះ[redacted]សង្កាត់ត្រពាំងក្រសាំង ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ប្តីឈ្មោះ[redacted] [redacted]ហាន កូន៥នាក់ ឪពុកឈ្មោ[redacted](ស)ម្តាយឈ្មោះ [redacted](ស)។ទោសពីមុនគ្មាន។ឃុំខ្លួនថ្ងៃទី០២-៣-២០១០។ខ្លួនមិនបានប្តឹងឧទ្ធរណ៍ទេ។បដិសេធចំលើយរបស់គាត់ដែលឆ្លើយនៅមុខប៉ូលីសរួចហើយ ព្រោះជាចំលើយដែលមានការបង្ខិតបង្ខំពីប៉ូលីសខ្លួនមានមុខរបរលក់ដូង២០ឆ្នាំហើយនៅផ្សារថ្មី។ខ្លួនមិនបានលក់កូនស្រីឲ្យទៅយុយក្រមុំទេ។ខ្លួនពុំបានលក់កូនទេ ហើយក៏ពុំដែលទាក់ទងភ្ញៀវណាដែរ ខ្លួនមិនដែលស្គាល់ហាងកាហ្វេមណ្ឌលគិរីទេ។ខ្លួនធ្លាប់ជំពាក់លុយធនាគារអេស៊ីលីដាមែន តែខ្លួនមិនលក់កូនទេ។ខ្លួនមិនដែលស្គាល់យាយផាងយាយពៅ និង យាយធីទេ។

ឈ្មោះ[redacted] ឆ្លើយថាៈខ្លួនជាអនុសេនីយឯក មានឋានៈនាយផ្នែកការិយាល័យប្រឆាំងការជួញដូរមនុស្ស និង ការពារអនិតិជន។ខ្លួនបានឃាត់ខ្លួនឈ្មោ[redacted]ផាង ឈ្មោះ[redacted] ពៅ និង ឈ្មោះ[redacted]ធី និង ជនរងគ្រោះ២នាក់ នេះនៅមុខសណ្ឋាគារឡាក់គីស្ការ។ពេលចុះ:



150

Scanned by CamScanner

68/4

ប្រតិបត្តិការណ៍មានគ្នា៧-៨នាក់។

ឈ្មោះ:[redacted]ហុង ឆ្លើយថា៖ខ្លួនជាអនុសេនីយត្រី មានឋានៈមន្ត្រីការិយាល័យប្រឆាំងការជួញដូរមនុស្ស និង ការពារអនិតិជន។ខ្លួនជាអ្នកសួរយកចំលើយឈ្មោ[redacted] ផាង ឈ្មោះ:ចែត ពៅ និង ឈ្មោ[redacted] ធី និង ជនរងគ្រោះ២នាក់នេះដោយផ្ទាល់ មិនបានចុះចាប់ទេ គឺកត់ត្រាតាមការឆ្លើយរបស់សាមីខ្លួន។ការសាកសួរ និង កត់ត្រាមានការណែនាំពីប្រធានអង្គភាព។

តំណាងមហាអយ្យការសន្និដ្ឋានថា៖ក្រោយពីបានពិនិត្យសំណុំរឿងព្រហ្មទណ្ឌលេខ ៨១/២០-០១-២០១១នេះ ក្រោយពីបានស្តាប់អំណានរបាយការណ៍ ក្រោយពីបានស្តាប់ចំលើយជនរងគ្រោះ ក្រោយពីបានស្តាប់ចំលើយរបស់ជនជាប់ចោទ ក្រោយពីបានពិនិត្យឯកសារ និង ភស្តុតាងនានា ឃើញថាជនជាប់ចោទឈ្មោះ:[redacted] ផាង ឈ្មោះ:[redacted]ពៅ និង ឈ្មោះ:[redacted]ធី បានប្តឹងឧទ្ធរណ៍ ឯជនជាប់ចោទ២នាក់ទៀតមិនបានប្តឹងឧទ្ធរណ៍ទេ។ក្នុងសំណុំរឿងខាងលើនេះសំអាងហេតុ និង សេចក្តីសំរេចមានលក្ខណៈត្រឹមត្រូវហើយ ទោះបីជនជាប់ចោទទាំងអស់ឆ្លើយបដិសេធចំលើយរបស់ខ្លួនក៏ដោយ តែហេតុ និង ផលវិបាក៍ទាក់ទងគ្នារហូត។ពិតមែនតែជនរងគ្រោះទាំង២បានឆ្លើយបដិសេធខ្លះវិញក៏ដោយ ក៏អង្គហេតុនៅតែទាក់ទិនគ្នាដដែល ប៉ូលីសចាប់បានតែអ្នកលក់ អ្នកទិញចាប់មិនបាន មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោ[redacted] ផាង.ឈ្មោះ [redacted] ធី. ឈ្មោះ:[redacted] ពៅ ពីបទអូសទាញពេស្យាចារកុមារ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៥.០២.២០១០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង ធ្វើអាជីវកម្មផ្លូវភេទ។ដូច្នេះសុំសំរេចតំកល់សាលក្រមព្រហ្មទណ្ឌលេខ១២៨ក្រ១/១៥.១១.២០១០របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការដដែល។

មេធាវី [redacted]ប៊ុនធឿន សន្និដ្ឋានថា៖ ខ្លួនជាមេធាវីការពារឲ្យឈ្មោះ:[redacted] ពៅ។ឈ្មោះ:[redacted] ពៅ ស្គាល់ឈ្មោះ:[redacted]ពៅ តាមការលក់ដូងម្តងម្កាល។កូនក្តីខ្លួនឈ្មោះ:[redacted] ពៅ បានឆ្លើយបដិសេធចំលើយរបស់គាត់ដែលឆ្លើយនៅមុខប៉ូលីសរួចហើយ ព្រោះជាចំលើយដែលមានការបង្ខិតបង្ខំពីប៉ូលីស។ឯឈ្មោះ:[redacted] ពៅ ក៏បានឆ្លើយដែរថា ពេលប៉ូលីសសួរយកចំលើយ មិនមានអាណាព្យាបាលនៅជិតទេ។ តាមចំលើយរបស់ឈ្មោះ:[redacted] ពៅ និង ឈ្មោះ:[redacted] ធីទៀត ម៉ាយ បានឆ្លើយថាមិនមានអ្នកណាអូសទាញពួកខ្លួនទេ គឺពួកខ្លួនស្ម័គ្រចិត្តដោយខ្លួនឯង ព្រោះចង់បានលុយយកជួយម្តាយ ព្រោះក្រពេក ។បទជួញដូរមនុស្សត្រូវមានអ្នកលក់ និង អ្នកទិញ។កូនក្តីខ្លួនឈ្មោះ:[redacted] ពៅ ឆ្លើយក្នុងសភាពភ័យខ្លាច ព្រោះប៉ូលីសបង្ខំ ដូច្នេះចំលើយទាំងអស់នេះមិនអាចយកជាបានការទេ។គ្មានភស្តុតាង និង សាក្សីណា១ដែលបញ្ជាក់ថាកូនក្តីខ្លួនបានប្រព្រឹត្តបទល្មើសទេ។សំណូមពរសុំបដិសេធសាលក្រមព្រហ្មទណ្ឌលេខ១២៨ក្រ១/១៥.១១.២០១០របស់សាលាដំបូងរាជធានីភ្នំពេញចោល និង សុំឲ្យកូនក្តីខ្លួនឈ្មោ[redacted] ពៅ បានរួចផុតពីបទចោទប្រកាន់ និង សុំឲ្យដោះលែងកូនក្តីខ្លួនឲ្យមានសេរីភាពវិញផង។



151

Scanned by CamScanner

មេធាវី [redacted] ឡុង សន្និដ្ឋានថា៖ ខ្លួនជាមេធាវីការពារឲ្យឈ្មោះ [redacted] ធី។ឆ្លងតាមការសួរដេញដោល សមត្ថកិច្ចចាប់ខ្លួនកូនក្តីខ្លួនឈ្មោះ [redacted] ធី ពេលកូនក្តីខ្លួនឈរនៅមុខសណ្ឋាគារ គឺសមត្ថកិច្ចចាប់ដោយសារមានការសង្ស័យប៉ុណ្ណោះ មិនមែនជាបទល្មើសជាក់ស្តែងទេ។តាមចំលើយរបស់ឈ្មោះ [redacted] ពៅ និង ឈ្មោះ [redacted] ធីទៀកម៉ាយ បានឆ្លើយថាមិនមានអ្នកណាអូសទាញពួកខ្លួនទេ គឺពួកខ្លួនស្ម័គ្រចិត្តដោយខ្លួនឯង ព្រោះចង់បានលុយយកជួយម្តាយ ព្រោះក្រពេក ។បទជួញដូរមនុស្សត្រូវមានអ្នកលក់ និង អ្នកទិញ ។កូនក្តីខ្លួនឈ្មោះ [redacted] ធី ឆ្លើយក្នុងសភាពតក់ស្លុត ព្រោះប៉ូលីសបង្ខំ ដូច្នេះចំលើយទាំងអស់នេះមិនអាចយកជាបានការទេ។គ្មានភស្តុតាង និង សាក្សីណាមួយដែលបញ្ជាក់ថាកូនក្តីខ្លួនបានប្រព្រឹត្តបទល្មើសទេ។សំណូមពរសុំបដិសេធសាលក្រមព្រហ្មទណ្ឌលេខ១២៨ក្រ១/១៥.១១.២០១០របស់សាលាដំបូងរាជធានីភ្នំពេញចោល និង សុំឲ្យកូនក្តីខ្លួនឈ្មោះ [redacted] ធីបានរួចផុតពីបទចោទប្រកាន់ និង សុំឲ្យដោះលែងកូនក្តីខ្លួនឲ្យមានសេរីភាពវិញផង។

មេធាវី [redacted] សុត្ថា សន្និដ្ឋានថា៖ខ្លួនជាមេធាវីការពារឈ្មោះ [redacted] ផាង។សមត្ថកិច្ចចាប់ខ្លួនកូនក្តីខ្លួនឈ្មោះ [redacted] ផាង ពេលកូនក្តីខ្លួនឈរនៅមុខសណ្ឋាគារ គឺសមត្ថកិច្ចចាប់ដោយសារមានការសង្ស័យប៉ុណ្ណោះ មិនមែនជាបទល្មើសជាក់ស្តែងទេ។តាមចំលើយរបស់ឈ្មោះ [redacted] ពៅ និង ឈ្មោះ [redacted] ធីទៀកម៉ាយ បានឆ្លើយថាមិនមានអ្នកណាអូសទាញពួកខ្លួនទេ គឺពួកខ្លួនស្ម័គ្រចិត្តដោយខ្លួនឯង ព្រោះចង់បានលុយយកជួយម្តាយ ព្រោះក្រពេក ។បទជួញដូរមនុស្សត្រូវមានអ្នកលក់ និង អ្នកទិញ ។កូនក្តីខ្លួនឈ្មោះ [redacted] ផាង ឆ្លើយក្នុងសភាពខ្លាចភ័យ ព្រោះប៉ូលីសបង្ខំ ដូច្នេះចំលើយទាំងអស់នេះមិនអាចយកជាបានការទេ។គ្មានភស្តុតាង និង សាក្សីណាមួយដែលបញ្ជាក់ថាកូនក្តីខ្លួនបានប្រព្រឹត្តបទល្មើសទេ។សំណូមពរសុំបដិសេធសាលក្រមព្រហ្មទណ្ឌលេខ១២៨ក្រ១/១៥.១១.២០១០របស់សាលាដំបូងរាជធានីភ្នំពេញចោល និង សុំឲ្យកូនក្តីខ្លួនឈ្មោះ [redacted] ពៅ បានរួចផុតពីបទចោទប្រកាន់ និង សុំឲ្យដោះលែងកូនក្តីខ្លួនឲ្យមានសេរីភាពវិញផង។

មេធាវី [redacted] សារឿន សន្និដ្ឋានថា៖ខ្លួនជាមេធាវីតំណាងឲ្យជនរងគ្រោះឈ្មោះ [redacted] ពៅ និង [redacted] ធីទៀកម៉ាយ ជាអនីតិជន។នៅក្នុងសំណុំរឿងមានភស្តុតាងលិខិតបញ្ជាក់ពីព្រហ្មចារីរបស់ជនរងគ្រោះទាំង២នាក់ ដែលជនជាប់ចោទទាំង៣នាក់ជាអ្នកដឹកនាំអូសទាញឲ្យទៅលក់ផ្លូវភេទ។ ទោះបីជនជាប់ចោទទាំងអស់ឆ្លើយបដិសេធចំលើយរបស់ខ្លួនក៏ដោយ តែហេតុ និង ផលរាបានទាក់ទងគ្នារហូត។ដូច្នេះសុំសំរេចតំកល់សាលក្រមព្រហ្មទណ្ឌលេខ១២៨ក្រ១/១៥.១១.២០១០របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការដដែល។

ក្រោយពីបានស្តាប់ចំលើយជនជាប់ចោទ.

ក្រោយពីបានស្តាប់ចំលើយជនរងគ្រោះ.

ក្រោយពីបានស្តាប់តំណាងមហាអយ្យការសន្និដ្ឋាន.

ក្រោយពីបានស្តាប់មេធាវីសន្និដ្ឋានការពារ.

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ.





Scanned by CamScanner

**<u>សំអាងហេតុ</u>**

១-បណ្តឹងឧទ្ធរណ៍លេខ៨៥៥ចុះថ្ងៃទី២៥-១១-២០១០របស់ជនជាប់ចោទឈ្មោះ [redacted]ពៅ បណ្តឹងឧទ្ធរណ៍លេខ៨៥៩ចុះថ្ងៃទី២៦-១១-២០១០របស់ជនជាប់ចោទឈ្មោះ [redacted]ធី បណ្តឹងឧទ្ធរណ៍លេខ៨៦១ចុះថ្ងៃទី២៩-១១-២០១០របស់ជនជាប់ចោទឈ្មោះ [redacted] ផាង បណ្តឹងឧទ្ធរណ៍លេខ៩០០ចុះថ្ងៃទី១៣-១២-២០១០លោក[redacted]សារឿន ជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted] ឌីក ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ១២៨ក្រ១/១៥.១១.២០១០របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ យោងមាត្រា៣៧៦ និង មាត្រា៣៨២នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជំរះបាន។

២-ជនជាប់ចោទឈ្មោះ[redacted]ផាង.ឈ្មោះ[redacted]ធី និង ឈ្មោះ[redacted]ពៅបានឆ្លើយបដិសេធមិនទទួលស្គាល់នូវអំពើប្រព្រឹត្តរបស់ខ្លួនទេ ប៉ុន្តែការឆ្លើយដោះសារនេះពុំមានមូលដ្ឋានគ្រប់គ្រាន់ដើម្បីពិចារណាឡើយ។

៣-តាមចំលើយរបស់ជនរងគ្រោះឈ្មោះ[redacted] ធីទៀកម៉ាយ និង[redacted]ពៅ បានឆ្លើយថា ពេលខ្លួនចង់ឃុយក្រមុំ គឺឈ្មោ[redacted] ធី និង [redacted]ពៅ បាននាំខ្លួនទៅពិនិត្យឈាម និង ប្រដាប់ភេទ ហើយបាននាំខ្លួនទៅជួបភ្ញៀវនៅសណ្ឋាគារឡាក់គីស្តារ ក៏ត្រូវសមត្ថកិច្ចធ្វើការចាប់ខ្លួនប្រាកដមែន។

៤-អំពើ និង សកម្មភាពរបស់ជនជាប់ចោទឈ្មោះ[redacted] ផាង.ឈ្មោ[redacted] ធី. ឈ្មោះ[redacted]ពៅ ពិតជាបានបញ្ចុះបញ្ចូលនាំជនរងគ្រោះទៅលក់ព្រហ្មចារីមែន ដែលអំពើនេះមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង ធ្វើអាជីវកម្មផ្លូវភេទ។

៥.រឿងក្តីនេះសាលាដំបូង បានលើកយកសំអាងហេតុមកបញ្ជាក់មានលក្ខណៈគ្រប់គ្រាន់ហើយ ហេតុនេះសភាព្រហ្មទណ្ឌឯកភាពតាមសំអាងហេតុនេះ ពុំចាំបាច់លើកយកសំអាងហេតុដដែលនេះមកបញ្ជាក់ជាថ្មីទៀតឡើយ។

៥.មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ[redacted] ផាង .ឈ្មោ[redacted] ធី. ឈ្មោះ[redacted]ពៅ ពីបទអូសទាញពេស្យាចារកុមារ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៥.០២.២០១០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង ធ្វើអាជីវកម្មផ្លូវភេទ។

៧-សាលក្រមព្រហ្មទណ្ឌលេខ១២៨ក្រ១/១៥.១១.២០១០របស់សាលាដំបូងរាជធានីភ្នំពេញ សំរេចសេចក្តីមានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និង គតិច្បាប់ហើយគប្បីសភាព្រហ្មទណ្ឌសំរេចតំកល់ទុកជាបានការ។





Scanned by CamScanner

68/1

## ហេតុដូច្នេះ ឧនិច្ឆ័យសេចក្តី

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ៨៨៥ចុះថ្ងៃទី២៥-១១-២០១០របស់ជនជាប់ចោទឈ្មោះ [redacted] ពៅ បណ្តឹងឧទ្ធរណ៍លេខ៨៥៩ចុះថ្ងៃទី២៦-១១-២០១០របស់ជនជាប់ចោទឈ្មោះ [redacted] ធី បណ្តឹងឧទ្ធរណ៍លេខ៨៦១ចុះថ្ងៃទី២៩-១១-២០១០របស់ជនជាប់ចោទឈ្មោះ [redacted] ផាង បណ្តឹងឧទ្ធរណ៍លេខ៩០០ចុះថ្ងៃទី១៣-១២-២០១០របស់លោក [redacted] សារឿន ជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឌឹក ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-តំកល់សាលក្រមព្រហ្មទណ្ឌលេខ១២៨ក្រ១/១៥.១១.២០១០របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការដដែល។

៤-បន្តការឃុំខ្លួនជនជាប់ចោទតាមច្បាប់។

៥.សាលដីកានេះជំនុំជំរះនៅថ្ងៃទី១៣-១០-២០១១ ថ្ងៃទី០៨-១២-២០១១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៦-១២-២០១១ ចំពោះមុខមេធាវីការពារសិទ្ធិជនជាប់ចោទ ជនជាប់ចោទ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និង ជនរងគ្រោះ។

បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់។

**ក្រឡាបញ្ជី** ហត្ថលេខា [redacted]

**ចៅក្រមប្រឹក្សា** ហត្ថលេខា [redacted]

**ប្រធានក្រុមប្រឹក្សាជំនុំជំរះ** ហត្ថលេខា [redacted]

---

បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម

សាលាឧទ្ធរណ៍ ថ្ងៃទី 20 ខែ 01 ឆ្នាំ២០១២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជំរះ**

[redacted]





Scanned by CamScanner